long beach unified school district

**OFFICE OF EQUITY, ACCESS, COLLEGE & CAREER READINESS**
**Volunteers in Public Schools**

VIPS *make a difference*

Parent University

# របៀបត្រូវធ្វើតាមសម្រាប់ការដាក់ពាក្យស្នើសុំជា អ្នកស្ម័គ្រចិត្ត (VIPS)

## ការបំពេញក្រដាសដាក់ពាក្យ គឺតម្រូវធ្វើ បួន ឆ្នាំម្តង

**មុខងារខុសត្រូវនៃអ្នកស្ម័គ្រចិត្តថ្មី**

**អ្នកស្ម័គ្រចិត្ត ដែលមានបំណងជួយ គឺត្រូវធ្វើតាមចំណុចដូចតទៅ ...**

**ឆ្លើយបំពេញ**ក្រដាសដាក់ពាក្យ VIPS ជាភាសា អង់គ្លេស ឬ ខ្មែរ ។

**ទៅសុំយក**ក្រដាសភស្តុតាងនៃរោគរបេងពីវេជ្ជបណ្ឌិត ដែលធ្វើការជោះស្បែក, នៅតាមមន្ទីរសុខភាព ដែលមានឈ្មោះវាយនៅភ្ជាប់ក្រដាសនេះ ឬ ក្រសួងអប់រំ ឱស្រ្ទីត ដែលបានធ្វើការជោះស្បែក ដោយមិនគិតថ្លៃ ។ ភស្តុតាងនៃរោគរបេង គឺត្រូវបញ្ជាក់អំពី **ថ្ងៃ/ខែ បានធ្វើការជោះស្បែក, ថ្ងៃ/ខែ បានពិនិត្យការជោះស្បែក (ចន្លោះ 48-72 ម៉ោង), លទ្ធផលនៃការជោះស្បែក** និង **ឈ្មោះនៃបន្ទីរពេទ្យ** ។ បើមិនចង់ជោះស្បែកទេ គឺអ្នកអាចប្រើមធ្យោបាយម្យ៉ាងជំនួសវិញបាន ដោយឆ្លើយបំពេញក្រដាសសំនួរអំពីរោគរបេងផ្ទាល់ខ្លួនរបស់អ្នក **ក្រោមការពិនិត្យនៃបុគ្គលិកពេទ្យ ដែលមានសញ្ញាប័ត្រខ្ពស់** ។ សម្រាប់ការពន្យល់អំពី x-ray គឺសូមទាក់ទងតាមទូរស័ព្ទលេខ (562) 997-8307 ។ សូមចំណាំថា លទ្ធផលល្អអំពីការពិនិត្យរោគរបេង គឺត្រូវមានការបង្ហាញក្នុងរយៈពេល 60 ថ្ងៃ បន្ទាប់ពីបានផ្ញើបញ្ជូនក្រដាសដាក់ពាក្យទៅកាន់ការិយាល័យ VIPS ផុតទៅ ។

យកក្រដាសដាក់ពាក្យ VIPS ពេញលេញត្រឹមត្រូវ, ក្រដាស គូពី នៃប័ណ្ណសំគាល់ខ្លួន និងក្រដាសភស្តុតាងនៃរោគរបេងទៅប្រគល់ជូនអ្នកចាត់ចែងកិច្ចការ VIPS នៅតាមសាលារៀន ។ ពត៌មានបង្ហាញមិនគ្រប់គ្រាន់ គឺនឹងធ្វើឲ្យមានការពន្យារពេល ។ បើអ្នកមានបំណងធ្វើការស្ម័គ្រនៅតាមសាលារៀនដាច់ៗពីគ្នា គឺ**ក្រដាសដាក់ពាក្យសម្រាប់សាលារៀននិមួយៗ ត្រូវតែឆ្លើយបំពេញ** ។

- អ្នកចាត់ចែងកិច្ចការ VIPS នៅតាមសាលារៀននឹងផ្ញើបញ្ជូនក្រដាសផ្នែកខាងក្រោមនេះទៅកាន់ការិយាល័យ Equity, Access, and College & Career Readiness នៃក្រសួងអប់រំ ឱស្រ្ទីត (LBUSD):

1. ក្រដាសបំពេញដាក់ពាក្យ VIPS ត្រឹមត្រូវ
2. ក្រដាសបង្ហាញលទ្ធផលនៃរោគរបេង ឬ ក្រដាសឆ្លើយសំនួរ ហៅ TB Risk Assessment Questionnaire Certificate of Completion
3. គូពី នៃប័ណ្ណសំគាល់ខ្លួន ដូចជា: ប័ណ្ណបើកបរ, ប័ណ្ណ ID

- ការិយាល័យ ឱស្រ្ទីត នឹងទទួលស្គាល់ក្រដាសដាក់ពាក្យជាផ្លូវការ, សើរើមើលភស្តុតាងនៃរោគរបេង និង ជីវប្រវត្តិនៃអ្នកសុំដាក់ពាក្យស្របច្បាប់ Megan's Law ។

- ការិយាល័យ ឱស្រ្ទីត នឹងផ្ញើបញ្ជូនលិខិតទទួលស្គាល់ និង ផ្លាកឈ្មោះនៃអ្នកស្ម័គ្រចិត្តទៅកាន់អ្នកចាត់ចែងកិច្ចការ VIPS នៅតាមសាលារៀន ។

- អ្នកចាត់ចែងកិច្ចការ VIPS នៅតាមសាលារៀននឹងទាក់ទងអ្នកស្ម័គ្រចិត្ត ហើយអ្នកស្ម័គ្រចិត្តអាចចាប់ផ្តើមជួយកិច្ចការបានភ្លាមនៅតាមសាលារៀន បន្ទាប់ពីបានចូលរួមស្តាប់នៅក្នុងកម្មវិធីពន្យល់ និង បានទទួលការចែកផ្តល់ជាសៀវភៅពត៌មាន (handbook) ផុតទៅ ។

- ដើម្បីការពារភាពសន្តិសុខសំរាប់សិស្ស គឺអ្នកត្រូវពាក់ផ្លាកឈ្មោះ VIPS ID badge **គ្រប់ពេលវេលា** ។ **ហាម**មិនឲ្យយកផ្លាកឈ្មោះចេញពីសាលារៀន (លើកលែងតែពេលធ្វើដំណើរទៅជាមួយសិស្ស) ឬ ប្រគល់ឲ្យមនុស្សផ្សេងខ្ចីប្រើ ។ អ្នក**ត្រូវ**កត់ឈ្មោះទាំងពេលចូល ទាំងពេលចេញ រៀងរាល់ថ្ងៃនៅក្នុងសាលារៀន ។

**អ្នកស្ម័គ្រចិត្តត្រឡប់ចូលវិញ, អតីតអ្នកស្ម័គ្រចិត្ត ឬ អ្នកស្ម័គ្រចិត្ត ដែលផ្លាស់ទៅធ្វើនៅតាមសាលារៀនផ្សេងវិញ**

1. **<u>បើត្រឡប់ចូលសាលារៀនដដែល</u>** – សូមណាត់ពេលជួបអ្នកចាត់ចែងកិច្ចការ VIPS នៅតាមសាលារៀន ដើម្បីសើរើមើល ថ្ងៃ/ខែ នៃលទ្ធផលពិនិត្យរោគរបេងរបស់អ្នក ។ បើវានៅមិនទាន់ហួសកម្រិតថ្ងៃ/ខែទេ គឺអ្នកអាចចាប់ផ្តើមស្ម័គ្រជួយបានភ្លាម ។ ការបំពេញក្រដាសថ្មី គឺតម្រូវ បួន ឆ្នាំម្តង ។

2. **<u>បើផ្លាស់ទៅសាលារៀនផ្សេង</u>** – **អ្នកស្ម័គ្រចិត្តត្រូវបំពេញក្រដាសដាក់ពាក្យថ្មី** ។ បន្ទាប់ពីនាយកសាលាបានចុះហត្ថលេខាទទួលស្គាល់ហើយ គឺអ្នកចាត់ចែងកិច្ចការ VIPS នៅតាមសាលារៀននឹងផ្ញើបញ្ជូនក្រដាសដាក់ពាក្យថ្មីទៅកាន់ការិយាល័យ ឱស្រ្ទីត ។ លទ្ធផលនៃរោគរបេង គឺនឹងមិនត្រូវការទេ ឲ្យតែវាមិនទាន់ហួសកម្រិតថ្ងៃ/ខែ ។ បន្ទាប់ទៅ, ក្រដាសដាក់ពាក្យនឹងទទួលការសើរើមើល ហើយលិខិតទទួលស្គាល់នឹងផ្ញើទៅកាន់សាលារៀនវិញ ដែលមានភ្ជាប់ផងទាំងផ្លាកឈ្មោះ ។ **ផ្លាកឈ្មោះពីសាលារៀនមួយទៅកាន់សាលារៀនមួយផ្សេង គឺមិនអាចប្រើការបាន** ។

**បើលទ្ធផលនៃរោគរបេងបានហួសកម្រិតថ្ងៃ/ខែផុតទៅ (បួន ឆ្នាំ សំរាប់ការជោះស្បែក ឬ ការឆ្លើយបំពេញសំនួរលើកក្រដាស) គឺ**ក្រដាសដាក់ពាក្យថ្មីនឹងត្រូវបំពេញ ។ ភស្តុតាងនៃរោគរបេងត្រូវបញ្ជាក់អំពី ថ្ងៃ/ខែ បានធ្វើ, ថ្ងៃ/ខែបានពិនិត្យឡើងវិញ (ចន្លោះ 48-72 ម៉ោង), លទ្ធផលល្អ/មិនល្អ និង ឈ្មោះមន្ទីរពេទ្យ ។ សម្រាប់ពត៌មានអំពី x-ray … សូមទាក់ទងតាមទូរស័ព្ទលេខ (562) 997-8307 ។

**អាសយដ្ឋានក្នុងប័ណ្ណបើកបរ ឬ ID គឺ**ត្រូវមានភាពដូចគ្នាជាមួយការសរសេរបង្ហាញនៅលើក្រដាសដាក់ពាក្យ ។ បើអ្នកផ្លាស់កន្លែងរស់នៅ គឺអ្នកត្រូវបង្ហាញភស្តុតាងអំពីអាសយដ្ឋានថ្មី ។ **ចំណែករូបថតក្នុងប័ណ្ណ បើកបរ ឬ ID វិញ គឺត្រូវមានភាពច្បាស់លាស់** ។

*ការចាត់ចែងក្រដាស VIPS នឹងត្រូវចំណាយពេលប្រហែល ពីរ សប្តាហ៍ ឬ លើស ។ សូមលៃលកពិនិត្យអំពីពត៌មានផ្សេងៗ ដែលត្រូវឆ្លើយបំពេញ និង ចុះហត្ថលេខាត្រឹមត្រូវសម្រាប់បង្ហាញនៅ លើក្រដាស ដើម្បីជៀសវាងការពន្យារពេល ។ សូមអរគុណចំពោះចិត្តអត់ធ្មត់ពីអ្នក ។

*សូមចំណាំថា ក្រដាសដាក់ពាក្យទាំងឡាយណា ដែលបង្ហាញការជាប់ទោស គឺតម្រូវឲ្យមានការខ្វាស់ភ្ជាប់មកផងអំពីក្រដាសពីតុលាការ និង តម្រូវពេលយូរបន្តិចសម្រាប់ការធ្វើតាមដាន ។

បើមានសំនួរអ្វីអំពីក្រដាសដាក់ពាក្យ គឺសូមទាក់ទងអ្នកស្រី Dulnari Edirisinghe-Aga តាមទូរស័ព្ទលេខ: (562) 997-8307 ។